**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# សុន្ទរកថាស្វាគមន៍
# និងរបាយការណ៍បូកសរុបលទ្ធផលសន្និបាតអប់រំ យុវជន និងកីឡា
# ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
# ថ្លែងក្នុង
# ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា
# ឆ្នាំសិក្សា ២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា ២០២៤-២០២៥

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

*សូមគោរព៖*

- *សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*
- *ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី*
- *អង្គសន្និបាតទាំងមូល ជាទីគោរពរាប់អាន!*

ថ្ងៃនេះជាទិវាប្រកបដោយនក្ខត្តឫក្សដែលយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយអង្គពិធីទាំងមូលមានកិត្តិយស សូមធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុង «ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា ២០២៤-២០២៥» នៅវេលានេះ។

ក្នុងឱកាសដ៏មហាប្រសើរនេះ ខ្ញុំបាទមានកិត្តិយសសូមការអនុញ្ញាតរាយការណ៍ជូន**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ព្រមទាំងអង្គសន្និបាតទាំងមូលអំពី៖ ទី១).សមិទ្ធផល និងកំណែទម្រង់សំខាន់ៗ ទី២).ការដោះស្រាយសំណួមពររៀនសូត្ររបស់សិស្ស និស្សិត និងយុវជន និងទី៣).ទិសដៅសម្រាប់ឆ្នាំសិក្សាបន្ត ដែលមានខ្លឹមសារដូចតទៅ៖

## I. ការអនុវត្តយុទ្ធសាស្ត្របញ្ញាកោណ ដំណាក់កាលទី១

ដើម្បីវាស់វែងសមិទ្ធកម្មអប់រំនៅក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ញាកោណ ដំណាក់កាលទី១ ក្រសួងជ្រើសរើសយកសូចនាករគន្លឹះចំនួនបី រួមមាន៖ ១).លទ្ធផលនៃកម្មវិធីវាយតម្លៃលទ្ធផលសិក្សារបស់ជាអន្តរជាតិ (PISA) ផ្តោតលើពិន្ទុជាមធ្យមនៃមុខវិជ្ជាអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ២).អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ និង ៣).អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។

### ១.១ ការអនុវត្តស្តង់ដាសាលារៀនគំរូ

នៅឆ្នាំទី២ នៃការលើកកម្ពស់អភិបាលកិច្ចសាលារៀន ជាពិសេសវិធានការគន្លឹះដែលបានដាក់ចេញដោយ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ក្រសួងបានបន្តអនុវត្តកំណែទម្រង់សាលារៀន និងបន្តកែលម្អយន្តការចុះជួយគាំទ្រសាលារៀនគំរូ ដោយប្រើប្រាស់ថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍ ផ្តោតលើ៖ លទ្ធផលសិក្សារបស់សិស្ស វិធីសាស្ត្របង្រៀននិងរៀន ការបណ្តុះបណ្តាល និងគាំទ្រគណៈគ្រប់គ្រងសាលារៀន ការចូលរួមរបស់សហគមន៍ និងការពង្រឹងគណនេយ្យភាពរបស់សាលារៀន។

ក្នុងសន្និបាតអប់រំឆ្នាំ ២០២៥នេះ ក្រសួងប្រកាសទទួលស្គាល់សាលារៀនចំនួន ១៤៤ ជាប់ស្តង់ដាសាលារៀនគំរូ រួមមាន៖ សាលាមត្តេយ្យសិក្សា ២៤ សាលាបឋមសិក្សា ៥០ (ក្នុងនោះសាលារៀនគោលដៅ គវអ. ចំនួន ១២) អនុវិទ្យាល័យ ៥ វិទ្យាល័យ ៦០ និងសាលាគរុកោសល្យ ៥។

ជាមួយគ្នានេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា (គវអ) បានពង្រីកសាលារៀនគោលដៅ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ ដោយប្រើប្រាស់យុទ្ធសាស្ត្រផ្ការីក ដល់សាលាបឋមសិក្សាចំនួន ១៦១ ក្នុង ២៥ រាជធានី ខេត្ត ផ្តោតលើកម្មវិធីក្រៅម៉ោងសិក្សាចំនួន ២ ម៉ោងបន្ថែម រួមមានវិន័យ សីលធម៌ ចរិយាធម៌ ការងារស្ម័គ្រចិត្ត និងការចូលរួមពីសហគមន៍។

### ១.២ ការលើកកម្ពស់គុណភាពអប់រំ

ភាគរយសិស្សប្រឡងជាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ស្ថិតក្នុងរង្វង់ ៩៥% នៅឆ្នាំសិក្សា ២០២៣-២០២៤។ ដោយឡែក លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០២៣-២០២៤បានបង្ហាញថា ភាគរយសិស្សប្រឡងជាប់បានកើនពី ៧៣% នៅឆ្នាំសិក្សា ២០២២-២០២៣ ដល់ ៧៩% នៅឆ្នាំសិក្សា ២០២៣-២០២៤។ បេក្ខជនទទួលបាននិទ្ទេស A សរុប ២.២២៥ នាក់។

ក្នុងឱកាសនេះដែរ ក្នុងនាមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមគាំទ្រអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ដែលបានលើកឡើងអំពី ការបន្តរួមចំណែកដល់ការលើកកម្ពស់គុណភាពវិស័យអប់រំនៅកម្ពុជា ជាពិសេសការចូលរួមអនុវត្តឱ្យបានជោគជ័យនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ សម្រាប់ការអភិវឌ្ឍមូលធនមនុស្ស ដោយ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដូចខាងក្រោម ៖

ទី១. លើកទឹកចិត្តឱ្យក្រសួងអប់រំ យុវជន និងកីឡា សហការជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបន្តធ្វើការកែទម្រង់ប្រព័ន្ធអភិវឌ្ឍមូលធនមនុស្សជាតិ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើចំណេះដឹង ជំនាញ និងបំណិនពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) សំដៅពង្រីកឧត្តមភាពប្រកួតប្រជែង និងពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា, ទាំងនៅកម្រិតតំបន់ និងសកល តាមរយៈការស្រាវជ្រាវ ការច្នៃប្រឌិត និងនវានុវត្តន៍។

ទី២. លើកទឹកចិត្តឱ្យក្រសួងអប់រំ យុវជន និងកីឡាបន្តលើកកម្ពស់គុណភាពអប់រំ ដោយចាប់ផ្តើមពីការលើកកម្ពស់គុណភាពគ្រូ គុណភាពនាយកសាលា ផ្តោតលើវិធីសាស្ត្របង្រៀន និងត្រូវបំពាក់សម្ភារៈបរិក្ខារឱ្យបានសមស្រប សម្រាប់ការអប់រំ និងការបង្ហាត់បង្រៀនឱ្យស្របទៅនឹងចក្ខុវិស័យនៃការអប់រំសតវត្សទី ២១។

ក្រសួងបានដាក់ចេញវិធានការដូចខាងក្រោម ដើម្បីលើកកម្ពស់គុណភាពអប់រំ៖

១. កែលម្អ**កម្មវិធីសិក្សា អភិវឌ្ឍសៀវភៅសិក្សា និងបង្កើនម៉ោងសិក្សា**ពី ៤ម៉ោង ក្នុង១ថ្ងៃ ទៅ ៦ម៉ោង ក្នុង១ថ្ងៃ ឬ ៤០ម៉ោង ក្នុង១សប្តាហ៍ សម្រាប់សាលាបឋមសិក្សាដែលមានសក្តានុពល។ ក្រៅពីនោះ ក្រសួងក៏បានជំរុញឱ្យសាលារៀនរៀបចំយន្តការ និងបង្កើតក្លឹបសិក្សា ដើម្បីឱ្យសិស្សធ្វើស្វ័យសិក្សា ជួយសិស្សរៀនយឺត និងអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា។

២. កែលម្អ**ការងារអធិការកិច្ច** ដែលជាកិច្ចការដ៏សំខាន់មួយក្នុងការគាំទ្រសាលារៀនគំរូ និងរៀបចំសកម្មភាពជាក់លាក់សម្រាប់ចុះជួយគាំទ្រសាលា។

៣. ពង្រឹងកិច្ចការ**វាយតម្លៃលទ្ធផលសិក្សា**របស់សិស្សនៅកម្រិតសាលារៀន និងជាមូលដ្ឋានសម្រាប់រៀបចំផែនការកែលម្អសាលារៀន ជាពិសេសផ្សារភ្ជាប់តេស្តកម្រិតតំបន់ SEA-PLM និងកម្រិតអន្តរជាតិ PISA ដើម្បីផ្សារភ្ជាប់វាយតម្លៃ ការសិក្សា កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងសៀវភៅសិក្សាគោល។

៤. ជំរុញឱ្យសាលារៀនគំរូឱ្យអនុវត្តវិធីសាស្ត្របង្រៀនថ្មី ដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មីដូចជា ការបង្រៀនតាមបែបគម្រោង និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន។

៥. ដាក់ឱ្យអនុវត្ត ការបង្រៀន និងរៀនពេញមួយថ្ងៃ នៅតាមគ្រឹះស្ថានសិក្សាដែលមានលទ្ធភាពសមស្រប ទាំងចំនួនបន្ទប់រៀន និងគ្រូបង្រៀន ក្នុងគោលដៅបង្កើនម៉ោងសិក្សា និងការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា។

៦. ជំរុញការអនុវត្ត កម្មវិធីក្រៅម៉ោងសិក្សា នៅតាមសាលារៀនគំរូ។

៧. ជំរុញការអនុវត្ត អំណាន និងគណិតវិទ្យាថ្នាក់ដំបូង ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់របស់សិស្សនៅបឋមសិក្សា និងភូមិសិក្សាបន្តបន្ទាប់ទៀត ដូចជា ១).ការលើកកម្ពស់អំណានថ្នាក់ដំបូងគណិតវិទ្យាថ្នាក់ដំបូង ២).ការបង្កើនចំនួនគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣, និង ៣).ការបង្កើតសាលាគំរូអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង។

## ១.៣ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន

ក្រសួងបានអនុម័តក្របខណ្ឌការងារមួយចំនួន សម្រាប់តម្រង់ទិសការងារបណ្តុះបណ្តាលគ្រូបង្រៀន រួមមាន៖ ផែនការយុទ្ធសាស្ត្រកំណែទម្រង់ការអប់រំគ្រូបង្រៀននៅប្រទេសកម្ពុជា ២០២៤-២០២៨ ស្តង់ដាសាលាគរុកោសល្យគំរូ និងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ។

ក្រសួងបានប្រកាសទទួលស្គាល់ឋានៈជាគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ និងបានបញ្ជូនគ្រូឧទ្ទេសទៅបន្តការសិក្សានៅប្រទេសជប៉ុន និងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ក្រសួងបានបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ តាមរយៈការប្រគល់សម្ភារៈបង្រៀន និងពិសោធន៍ ការកែលម្អអគារ បណ្ណាល័យ បន្ទប់ ICT និងសាលប្រជុំឌីជីថល នៅវិទ្យាស្ថានគរុកោសល្យ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ ដើម្បីលើកទឹកចិត្តដល់ការអនុវត្តកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ នៅក្នុងសន្និបាតអប់រំឆ្នាំ ២០២៥នេះ ក្រសួងបានទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូចំនួន ៥ ជាសាលាគរុកោសល្យគំរូ។

## ១.៤ ការលើកកម្ពស់ការអប់រំឌីជីថល និងការប្រើប្រាស់បញ្ញាសិប្បនិម្មិត

ក្រសួងបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ក្នុងគោលដៅលើកកម្ពស់អក្ខរកម្មឌីជីថល ការអនុវត្តប្រព័ន្ធគ្រប់គ្រងការសិក្សា ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់បច្ចេកវិទ្យាឌីជីថល ការបង្កើតនិងកែសម្រួលកម្មវិធីបណ្តុះបណ្តាលលើមុខជំនាញ

ផ្នែកបច្ចេកវិទ្យាឌីជីថល និងការពង្រីកនិងការប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការបង្រៀន និងរៀន។

ថ្មីៗនេះ ក្រសួងបានសហការជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីរៀបចំសន្និសីទ និងពិព័រណ៍បច្ចេកវិទ្យាអប់រំកម្ពុជា លើកទី១ ក្រោមប្រធានបទ "មាគ៌ាកម្ពុជាឆ្ពោះទៅកាន់ការអប់រំឌីជីថល" និងបានដាក់ឱ្យអនុវត្តនូវគំនិតផ្តួចផ្តើមសំខាន់ៗ រួមមាន៖ ១).យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ២).គម្រោងអភិវឌ្ឍសមត្ថភាពអ្នករៀបចំគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាអប់រំ ៣).ការអភិវឌ្ឍសាលារៀនឌីជីថលកម្ពុជា ៤).ការអភិវឌ្ឍក្របខណ្ឌបញ្ញាសិប្បនិម្មិត (AI) នៅកម្រិតសាលារៀន និងគ្រឹះស្ថានអប់រំគ្រូបង្រៀន ៥).ការប្រកួតប្រជែងសមត្ថភាពបញ្ញាសិប្បនិម្មិត ៦).ការរៀបចំក្របខណ្ឌបច្ចេកវិទ្យាអប់រំ (EdTech Framework) ក្នុងការរៀន និងបង្រៀន ៧).បញ្ញាសិប្បនិម្មិតសម្រាប់ការអប់រំនិងការប្រកួតប្រជែងប្រកបដោយនវានុវត្តន៍ ៨).ការរៀបចំគន្លងសិក្សាថ្មីផ្សារភ្ជាប់ទៅនឹងបញ្ញាសិប្បនិម្មិត ក្របខណ្ឌការអប់រំស្វែមកម្រិតសាលារៀន និងគ្រូល្អបច្ចេកវិទ្យា។

ក្នុងបរិបទបច្ចុប្បន្ន **បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត** (AI) បានចូលរួមចំណែកនៅក្នុងការលើកកម្ពស់លទ្ធផលសិក្សា ជំរុញការប្រើប្រាស់វិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិត និងទំនើបកម្មសម្ភារៈសិក្សាក៏ដូចជាក្នុងទីផ្សារការងារ ក៏ប៉ុន្តែបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតក៏អាចជាបញ្ហាប្រឈមមួយសម្រាប់ប្រព័ន្ធអប់រំ នាពេលបច្ចុប្បន្ន។ ប្រព័ន្ធអប់រំមានតម្រូវការបន្ទាន់ ក្នុងការរួមបញ្ចូលកម្មវិធីបញ្ញាសិប្បនិម្មិតទៅក្នុងការអប់រំ ដើម្បីរៀបចំសិស្ស និស្សិត និងយុវជនឱ្យបានគត់មត់សម្រាប់ទីផ្សារការងារ ដែលកំពុងមានការវិវត្តជាបន្តបន្ទាប់។

បច្ចុប្បន្ននេះ សាលារៀនជំនាន់ថ្មីបានបញ្ចូលការប្រើប្រាស់បញ្ញាសិប្បនិម្មិតទៅក្នុងការបង្រៀន និងរៀន ដូចជាសិស្សប្រើប្រាស់ AI ដើម្បីស្វែងយល់មេរៀន ការប្រើប្រាស់ AI ដើម្បីពន្យល់ពីចំណុចដែលមិនយល់ច្បាស់ និងពន្យល់បន្ថែមតាមកម្រិតយល់ដឹងរបស់ខ្លួន ការទទួលបានជំនួយក្នុងការដោះស្រាយលំហាត់ ព្រមទាំងពិនិត្យចម្លើយ និងរកកំហុសផងដែរ។ គ្រូបង្រៀនប្រើប្រាស់ AI ដើម្បីរៀបចំមេរៀន និងកិច្ចតែងការបង្រៀន ការប្រើប្រាស់ AI ដើម្បីពិនិត្យកិច្ចការរបស់សិស្ស កាត់បន្ថយការប្រើប្រាស់ពេលពេលវេលាក្នុងការផលិតធនធានបង្រៀន ព្រមទាំងជួយដល់ការងាររដ្ឋបាលសិក្សាផ្សេងៗ ដូចជា៖ ការបកប្រែភាសា ការស្វែងរកព័ត៌មាន ការសរសេរអត្ថបទ ការបង្កើតមេរៀន សំណួរ វីដេអូបង្រៀន ផលិតរូបភាពដើម្បីប្រើប្រាស់ក្នុងការបង្រៀន និងល្បែងសិក្សា ។ល។

ជាមួយគ្នានេះ វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យក៏បានបញ្ចូលការប្រើប្រាស់បញ្ញាសិប្បនិម្មិតទៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ដូចជាការបង្កើតកិច្ចតែងការបង្រៀន ការបង្កើតស្លាយ PowerPoint ការដោះស្រាយបញ្ហា ការបង្កើតគម្រោងផ្សេងៗ ការបង្កើតកម្រងសំណួរ ដូចជា ពហុជ្រើសរើស ការបង្កើតសំណួរពិភាក្សាកម្រិតខ្ពស់ (High Order Thinking) និងការប្រើប្រាស់ AI ដើម្បីបង្កើតសម្លេង។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានបង្កើតកម្មវិធីសញ្ញាបត្រវិស្វកម្មលើបញ្ញាសិប្បនិម្មិត (AI) និង Cybersecurity វិស្វកម្មផ្នែកទន់ និងវិទ្យាសាស្ត្រទិន្នន័យ។ ក្រុមជំនាញរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាក៏ធ្វើបានធ្វើការស្រាវជ្រាវ និងអភិវឌ្ឍលើ AI ដូចជា ការសម្គាល់អត្ថបទ ការស្គាល់រូបភាព និងការស្គាល់ចលនា ព្រមទាំងមានករណីសិក្សាស្រាវជ្រាវលើការប្រើប្រាស់ឧបករណ៍ AI សម្រាប់ "បណ្ណាល័យឌីជីថលស្លឹកត្នោតខ្មែរ" និង "ជំនួយការបង្រៀន និងការបង្រៀនខ្មែរ"។ បណ្ណាល័យរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានប្រើប្រាស់ ChatGPT និង ResearchRabbit សម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួន ហើយក៏ជាសៀវភៅកាតាឡុកសម្រាប់ប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ និងសេវាកម្មយោងនៅក្នុងបណ្ណាល័យ ព្រមទាំងបានប្រើប្រាស់កម្មវិធី myGPT ក្នុង ChatGPT AI ដើម្បីបង្កើតមុខងារតូចមួយជាមនុស្សយន្តដែលជួយបណ្ណាល័យក្នុងការធ្វើកាតាឡុក។ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានលើកទឹកចិត្តសិស្ស សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវឱ្យប្រើប្រាស់ GenAI (ResearchRabbit, Elicit, PaperDigest,) ដើម្បីធ្វើសេវាកម្មយោងសម្រាប់ការសម្របសម្រួលពួកគេ ដើម្បីធ្វើការស្រាវជ្រាវលើប្រធានបទជាក់លាក់។ ដោយឡែក សាកលវិទ្យាល័យជាតិគ្រប់គ្រង នឹងដាក់បញ្ចូលបញ្ញាសិប្បនិម្មិត (AI) នៅគ្រប់មុខជំនាញ។

ក្រសួងនឹងដាក់ចេញនូវវិធានការមួយចំនួន ដូចជា៖ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន សមត្ថភាពសិស្ស និងនិស្សិតផ្ទើមលើផ្នែកបច្ចេកវិទ្យា ការធ្វើបរិវត្តកម្ម ការធ្វើទំនើបកម្មសម្ភារៈឌីជីថល ព្រមទាំងការវិនិយោគលើបុគ្គលដែលមានសមត្ថភាព មានទេពកោសល្យ និងមានការប្តេជ្ញាចិត្តខ្ពស់ការអនុវត្តវិធីសាស្ត្របង្រៀនបែបថ្មីស្របតាមបំណិនសតវត្សទី២១ និងការធ្វើកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ។ ក្រសួងមានទិសដៅបញ្ជ្រាបបច្ចេកវិទ្យាអប់រំ និងបញ្ញាសិប្បនិម្មិត (AI) ដែលជាមធ្យោបាយជំនួយដល់ការរៀន និងការបង្រៀន។ គ្រូបង្រៀននៅតាមជនបទក៏អាចប្រើប្រាស់បច្ចេកវិទ្យា ក្នុងការបង្រៀនបានល្អប្រសើរផងដែរ ប្រសិនបើគ្រូបង្រៀនមានផ្នត់គំនិត និងការប្តេជ្ញាចិត្តទទួលយកបច្ចេកវិទ្យាអប់រំថ្មី។ ចំណុចខាងលើនេះទាមទារនូវកិច្ចសហការគ្នាពីគ្រប់ភាគីពាក់ព័ន្ធ។ ក្រសួងនឹងរៀបចំយន្តការវាយតម្លៃទទួលស្គាល់គ្រូល្អ បង្រៀនបច្ចេកវិទ្យា រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីដោះស្រាយបញ្ហាខ្វះគ្រូ និងខ្វះបន្ទប់រៀន។

ក្រសួងបានសម្ពោធឱ្យអនុវត្តជាផ្លូវការ **សាលារៀនឌីជីថលកម្ពុជា** ដែលជាការបើកទំព័រថ្មីសម្រាប់វិស័យអប់រំ ដោយសារសាលារៀនឌីជីថលកម្ពុជា មិនមែនគ្រាន់តែដាក់បញ្ចូលបច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត ក្នុងការរៀន ការបង្រៀន និងអភិបាលកិច្ចសាលារៀននោះទេ ប៉ុន្តែជាការបើកទំព័រថ្មីមួយសម្រាប់វិស័យអប់រំ ដែលផ្តល់ឱកាសឱ្យសិស្សទទួលបានឱកាសសិក្សាគ្មានដែនកំណត់ឆ្ពោះទៅកាន់អនាគតដ៏រុងរឿង។ លក្ខណៈពិសេសរបស់សាលារៀនឌីជីថលគឺ ការផ្តល់ជូននូវថ្នាក់រៀននិម្មិត និងថ្នាលសិក្សាបែបអន្តរកម្ម ដែលសិស្សានុសិស្សអាចសិក្សាតាមប្រព័ន្ធឌីជីថលមានភាពបត់បែន និងអាចផ្តល់នូវមេរៀនទៅតាមរបៀបរៀន និងល្បឿននៃការសិក្សារៀងៗខ្លួន ដោយផ្សារភ្ជាប់សាលារៀនជំនាន់ថ្មីជាមួយសាលារៀនគំរូ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

## ១.៥ ការលើកកម្ពស់សុខភាពសិក្សា និងការបង្កើនអាហារូបករណ៍

ជាផ្នែកមួយនៃក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម កម្មវិធីផ្តល់អាហារតាមសាលារៀននៅកម្ពុជាត្រូវបានអនុវត្តនៅតាមសាលារៀនគោលដៅសរុបចំនួន ១,១១៤ សាលា ក្នុងខេត្តចំនួន ១០ និងមានសិស្សទទួលផលប្រមាណ ៣០០,០០០នាក់ គិតចាប់ពីឆ្នាំ ២០១៩ រហូតមកដល់ឆ្នាំ២០២៤។ នៅក្នុងឆ្នាំ ២០២៤ កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានអនុវត្តនៅតាមសាលារៀនគោលដៅចំនួន ៥៥៣សាលា ក្នុងខេត្តចំនួន ១០ និងមានសិស្សទទួលផលចំនួន ១៥៣,៥៨៦នាក់ ។

ក្រសួងបានផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ សិស្សពូកែ និងសិស្សមានពិការភាពនៅបឋមសិក្សាចំនួន ១៤៨.៩០១ នាក់ មធ្យមសិក្សាបឋមភូមិចំនួន ១០២.៣៥៩ នាក់ មធ្យមសិក្សាទុតិយភូមិចំនួន ១១.១៦៧នាក់ និងនៅកម្រិតអប់រំពិសេសចំនួន ១.០៩០នាក់។

## ១.៦ ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា និងការលើកកម្ពស់ការស្រាវជ្រាវ

តាមរយៈឧត្តមានុវត្តន៍នៃការអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សា ក្រសួងបាន និងកំពុងអនុវត្តកំណែទម្រង់អាទិភាពមួយចំនួន ដូចខាងក្រោម៖

១). <u>ការកែលម្អប្រព័ន្ធអភិបាលកិច្ច និងភាពជាអ្នកដឹកនាំអនុវិស័យ និងគ្រឹះស្ថានឧត្តមសិក្សា</u> តាមរយៈការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការកសាងសមត្ថភាពអ្នកដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត ដើម្បីធានាបាននូវស្វ័យភាព តម្លាភាព និងគណនេយ្យភាព។ គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន ៦

ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

២. <u>ការកែលម្អគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំ</u> តាមរយៈ ១).ការអនុវត្តកម្មវិធីភាពជាដៃគូជាមួយសាកលវិទ្យាល័យអន្តរជាតិចំនួន ១៧ និងគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុកចំនួន ៤ បានកែលម្អកម្មវិធីសិក្សា ២).ការរៀបចំសេចក្តីព្រាងក្របខណ្ឌអប់រំអនាគតផលស្តីពី ការអប់រំផ្អែកលើលទ្ធផល (Outcome-Based Education) សម្រាប់ឧត្តមសិក្សាកម្ពុជា ការរៀបចំកម្មវិធីសិក្សាបរិវត្តន៍ (Transformative curriculum) ដែលផ្តល់ឱ្យនិស្សិតនូវចំណេះដឹង ជំនាញ និងអាកប្បកិរិយាល្អ និងមានលក្ខណៈទន់ភ្លន់ និងបត់បែន។

៣. <u>គ្រឹះស្ថានឧត្តមសិក្សា ១៨ (រដ្ឋ ១៣ ឯកជន ៥) បានចូលរួមអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា</u> ក្នុងនោះ គ្រូ និងបុគ្គលិកជំនាញចំនួន ២៥៥នាក់ បានទទួលការបណ្តុះបណ្តាល កម្មវិធីអប់រំចំនួន ១៩ មុខវិជ្ជាអនឡាញចំនួន ៥៦ ត្រូវជា ៣១៦មេរៀន ត្រូវបានដាក់ឱ្យដំណើរការ និងមាននិស្សិត ២.៤៥៤នាក់ បានចូលរៀន។

៤. អន្តេវាសិកដ្ឋាន ១ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានសាងសង់រួចរាល់ និង ៣ កន្លែងនៅគ្រឹះស្ថានផ្សេងទៀតកំពុងដំណើរការសាងសង់ អគារសិក្សាចំនួន ២ បានសាងសង់រួចរាល់ និងអគារ ៣ ទៀតកំពុងដំណើរការសាងសង់ ព្រមទាំងសាងសង់ និងជួសជុលបន្ទប់ពិសោធន៍ចំនួន ១៦៧ រួមទាំងអគារមជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្តុះបណ្តាលកសិកម្ម។

៥. ក្រសួងបានកសាងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវ តាមរយៈការសាងសង់ និងជួសជុលបន្ទប់ពិសោធន៍ ការបំពាក់បរិក្ខារ និងឧបករណ៍ស្រាវជ្រាវទំនើបៗ ការអភិវឌ្ឍសមត្ថភាព និងគុណវុឌ្ឍិអ្នកស្រាវជ្រាវ និងជំរុញការបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវជាតិ ឬអន្តរជាតិ។

៦. ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង គ្រឹះស្ថានឧត្តមសិក្សាចំនួន ៤៨ បានចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ដោយបានធ្វើស្វ័យវាយតម្លៃលើកម្មវិធីសិក្សាចំនួន ១០២ និងកម្មវិធីសិក្សាចំនួន ៣ ត្រូវបានវាយតម្លៃ និងទទួលស្គាល់ដោយបណ្តាញសាកលវិទ្យាល័យអាស៊ាន។

៧. បុគ្គលិកអប់រំនៅឧត្តមសិក្សាចំនួន ២០៣នាក់ (សិក្សានៅក្រៅប្រទេសចំនួន ១៤២ នាក់) បានបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ក្នុងនោះបរិញ្ញាបត្រជាន់ខ្ពស់ ១៤៧ នាក់ និងថ្នាក់បណ្ឌិត ៥៦នាក់។

៨. ក្រសួងបាន និងកំពុងពង្រីកការវិនិយោគលើការអប់រំឌីជីថល និងជំនាញថ្មីៗ រួមមាន ជំនាញសេដ្ឋកិច្ចឌីជីថល, វិស្វកម្មវិទ្យាសាស្ត្រទិន្នន័យ, ប្រព័ន្ធបញ្ញានិងបណ្តាញ អគ្គិសនី, មេកាត្រូនិក, អេឡិកត្រូនិក, វិស្វកម្ម Software, បញ្ញាសិប្បនិម្មិត (AI), សន្តិសុខសាយប័រ, រ៉ូបូទិកនិងស្វ័យប្រវត្តិកម្ម ។

## ១.៧ កំណែទម្រង់មុខងារសាធារណៈ

ក្រសួងបានបញ្ចប់ជាស្ថាពរនូវការវិភាគមុខងារ និងបានកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួងឱ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ក្រសួងបានពិនិត្យលើវិសេសភាព និងមុខងាររបស់អង្គភាព ដើម្បីរៀបចំបញ្ជីមុខតំណែងវិជ្ជាជីវៈមន្ត្រីអប់រំ ដើម្បីគាំទ្រលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការជ្រើសរើស និងការគ្រប់គ្រងមន្ត្រីតាមកិច្ចព្រមព្រៀង ការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈអប់រំ ។

ក្រសួងកំពុងរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គគ្រូបង្រៀន។

ក្រសួងបានសិក្សាលើ **ស្ថានភាពពង្រាយគ្រូបង្រៀន** និងដាក់ចេញវិធានការដោះស្រាយជាក់លាក់ ដើម្បីធានាបានការផ្តល់ និងការប្រើប្រាស់បុគ្គលិកអប់រំនៅកម្រិតសាលារៀនប្រកបដោយប្រសិទ្ធភាព ជាពិសេសដាក់ចេញនូវវិធានការកាត់បន្ថយជាបណ្តើរៗចំនួនសិស្សក្នុងបន្ទប់រៀន ដើម្បីធានាគុណភាពអប់រំ។

ក្រសួងបានរៀបចំ **ផែនការអភិវឌ្ឍធនធានមនុស្ស** ដើម្បីពង្រឹងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ដោយផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រូបង្រៀន អ្នកដឹកនាំនិងគ្រប់គ្រង អ្នកស្រាវជ្រាវ និងអ្នកវាយតម្លៃអប់រំ ព្រមទាំងបង្កើតយន្តការសម្រាប់តម្រង់ទិសការងារ ការចុះជួយបង្វឹកការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ផងដែរ។

ក្រសួងបានអនុម័តរួចហើយនូវក្របខណ្ឌគោលនយោបាយស្តីពី **គន្លងអាជីពគ្រូបង្រៀន** និងប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំង ក្របខណ្ឌនិងផែនការសកម្មភាពស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន។

### ១.៨ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ក្រសួងបាន និងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងបានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធី ដើម្បីឆ្លើយតបនឹងថវិកាសមិទ្ធកម្ម ការផ្សារភ្ជាប់រវាងគោលនយោបាយ ផែនការ និងថវិកា ក៏ដូចជាការបង្កើនគណនេយ្យភាពរបស់អង្គភាពថវិកា ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និងការពង្រឹងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ព្រមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្ម ផងដែរ។

## II. លទ្ធផលសម្រេចបានក្នុងឆ្នាំសិក្សា ២០២៣-២០២៤

ក្នុងផ្នែកបរិមាណ និងការដោះស្រាយសំណូមពររៀនសូត្ររបស់សិស្ស និស្សិត និងយុវជន ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ ចំនួនសាលារៀននៅទូទាំងប្រទេសសរុប ១៩.៥៩១ ក្នុងនោះសាលារៀនសាធារណៈមាន ១៣.៩៤៨សាលា សាលារៀនឯកជន ២.២៩៥ សាលា និងមត្តេយ្យសិក្សាសហគមន៍ ៣.៣៤៨កន្លែង។ គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១៩៤កន្លែង ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៧៩ និងគ្រឹះស្ថានឧត្តមសិក្សាឯកជន ១១៥។ សិស្ស និងនិស្សិតសរុប ៤.១៧១.៩៦២ នាក់ ក្នុងនោះ៖

១.កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាព ៤២៥.៥៣៩នាក់ ស្រី ៤៩.៨% និងអត្រាចូលរៀនកុមារអាយុ ៥ ឆ្នាំកើនឡើងពី ៦៥.៤% នៅឆ្នាំសិក្សា ២០២៣-២០២៤ ដល់ ៧១.៤% នៅឆ្នាំសិក្សា ២០២៤-២០២៥

២. សិស្សបឋមសិក្សាសរុប ២.២៦១.២១៦នាក់ ស្រី ៤៨% និងអត្រាពិតនៃការសិក្សាកើនឡើងពី ៩៩.៦% នៅឆ្នាំសិក្សា ២០២៣-២០២៤ ដល់ ១០២.៣% នៅឆ្នាំសិក្សា ២០២៤-២០២៥

៣. សិស្សមធ្យមសិក្សាបឋមភូមិសរុប ៧១២.២៩៨នាក់ ស្រី ៥២.១% និងអត្រារួមនៃការសិក្សាកើនឡើងពី ៦៥.៥% នៅឆ្នាំសិក្សា ២០២៣-២០២៤ ដល់ ៧៥.២% នៅឆ្នាំសិក្សា ២០២៤-២០២៥

៤. សិស្សមធ្យមសិក្សាទុតិយភូមិសរុប ៤៥៦.៨០៤នាក់ ស្រី ៥៥.៦% និងអត្រារួមនៃការសិក្សាកើនឡើងពី ៣៩.៣% នៅឆ្នាំសិក្សា២០២៣-២០២៤ ដល់ ៤៤.៣% ឆ្នាំសិក្សា ២០២៤-២០២៥ ក្នុងនោះសិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស ៣.៨៤០នាក់ ស្រី ៣៣.៦%

៥. និស្សិតឧត្តមសិក្សាសរុប ៣១៦.១០៥នាក់ ស្រី ៥២.៥% និងអត្រាចូលរួមនៃការសិក្សា (អាយុ១៨-២២ឆ្នាំ) កើនឡើងពី ១៧.៩% នៅឆ្នាំសិក្សា ២០២២-២០២៣ ដល់ ១៩.០៨% នៅឆ្នាំសិក្សា ២០២៣-២០២៤។

ក្រសួងបានបញ្ជូនកីឡាករទៅចូលរួមការប្រកួតកីឡាក្រៅប្រទេស កម្ពុជាទទួលបានមេដាយសរុប ២៦៩គ្រឿង (មេដាយមាស ៦៣ មេដាយប្រាក់ ៦២ មេដាយសំរឹទ្ធិ ១២៦) និងការប្រកួតកីឡាអន្តរជាតិក្នុងប្រទេស កម្ពុជាទទួលបានមេដាយ ១.៣១៦ គ្រឿង (មេដាយមាស ៣៨៦ មេដាយប្រាក់ ៣៩០ មេដាយសំរឹទ្ធិ ៥៤០)។

## III. ទិសដៅឆ្នាំសិក្សា ២០២៤-២០២៥

សន្និបាតអប់រំ យុវជន និងកីឡាឆ្នាំនេះបានដំណើរការចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីបូកសរុបវាយតម្លៃការងារ ដែលបានអនុវត្តក្នុងឆ្នាំសិក្សាកន្លងមក និងលើកទិសដៅការងារសម្រាប់ឆ្នាំសិក្សាខាងមុខទៀត។ មុននឹងរៀបចំសន្និបាតនៅថ្នាក់ជាតិនេះ ក្រសួងបានណែនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំងអស់ ឱ្យរៀបចំរបាយការណ៍សន្និបាត ដើម្បីប្រមូលធាតុចូលពីថ្នាក់ក្រោមជាតិ មកពិភាក្សាដោះស្រាយក្នុងសន្និបាតនៅថ្នាក់ជាតិ ដែលមានអ្នកចូលរួមផ្ទាល់ប្រមាណ ២០០០នាក់ និងមានអ្នកចូលរួមជាច្រើនទៀតតាមប្រព័ន្ធអនឡាញ។

សន្និបាតអប់រំឆ្នាំនេះ ក្រសួងបានជ្រើសរើសប្រធានបទ បទបង្ហាញ និងបទអន្តរាគមន៍ដែលមានខ្លឹមសារពាក់ព័ន្ធនឹងអភិបាលកិច្ចអប់រំ ការកែទម្រង់សាលារៀន បរិវត្តកម្មអប់រំឧត្តមសិក្សា និងបរិយាកាសល្អសម្រាប់ការអប់រំពេញមួយជីវិត។ តាមរយៈការពិភាក្សាយ៉ាងផុសផុល សន្និបាតអប់រំឆ្នាំ ២០២៥ បានដាក់ចេញនូវអាទិភាពការងារសម្រាប់អនុវត្តនៅក្នុងឆ្នាំសិក្សា ២០២៤-២០២៥ និងឆ្នាំសិក្សាបន្តបន្ទាប់ ដូចខាងក្រោម៖

***វេទិកាពិភាក្សាទី១៖ "អភិបាលកិច្ចអប់រំ"*** បានដាក់ចេញនូវទិសដៅការងារដូចខាងក្រោម៖

- សន្និបាតអប់រំគឺជាយន្តការត្រួតពិនិត្យ និងវាយតម្លៃ (M&E) ដែលក្រសួងបាន និងកំពុងអនុវត្ត ដោយផ្អែកលើការអនុវត្តថវិកាផ្តោតលើសមិទ្ធកម្ម។

១.សូចនាករសំខាន់ៗសម្រាប់វាយតម្លៃអភិបាលកិច្ចអប់រំនៅកម្រិតក្រសួងរួមមាន៖ ១).ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២).ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមគោលការណ៍អភិបាលកិច្ចល្អ ជាពិសេសការអនុវត្តសកម្មភាពរបស់អង្គភាពនីមួយៗ ៣).ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ដូចជាកំណែទម្រង់សាលាគរុកោសល្យ ការជ្រើសរើសនិងការបណ្តុះបណ្តាលគ្រូ ការគ្រប់គ្រងការប្រើប្រាស់គ្រូបង្រៀន និងការ

ចុះកិច្ចព្រមព្រៀងលទ្ធផលការងារ ៤).ការគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងបច្ចេកទេស ៥).ការប្រើប្រាស់បច្ចេកវិទ្យា និងទិន្នន័យ និង៦).ការពង្រឹងយន្តការពិនិត្យតាមដាន។

២. សូចនាករសំខាន់ៗសម្រាប់វាយតម្លៃអភិបាលកិច្ចអប់រំកម្រិតមន្ទីរ រួមមាន៖ ១).ការគ្រប់គ្រងរដ្ឋបាល ២).ការគ្រប់គ្រងបុគ្គលិក ដូចជាការពង្រាយគ្រូពីសាលាលើសទៅសាលាខ្វះ ការបែងចែកគ្រូចេញថ្មី និងធានាបាននូវផលធៀបសិស្ស-គ្រូបង្រៀនសមរម្យ ៣).ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជាការតាមដានការបើកបៀវត្សឱ្យទាន់ពេលវេលា ជាដើម ៤).ការគ្រប់គ្រងការរៀន និងការបង្រៀន។

៣. ដើម្បីពង្រឹងអភិបាលកិច្ចសាលារៀន ត្រូវផ្ដោតលើ ១).ការកែលម្អបរិស្ថាន ២).ការពង្រឹងវិន័យ សីលធម៌ និងការអប់រំវិជ្ជមានរិយាបថ ៣).ការពង្រឹងគុណភាពសិក្សារបស់សិស្ស ៤).ការគ្រប់គ្រងបុគ្គលិកប្រកបដោយប្រសិទ្ធភាព ៥).ការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន ៦).ការចូលរួមរបស់សហគមន៍ ៧).ការពង្រឹងថ្នាក់ពីរភាសា ៨).ការអភិវឌ្ឍគ្រូបង្រៀនឱ្យសម្រេចបានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

- ក្រសួងនឹងជំរុញការចាប់យកបញ្ញាសិប្បនិម្មិត (AI) ដើម្បីជាជំនួយដល់ការរៀន និងបង្រៀន ជាពិសេសដើម្បីបង្កើនប្រសិទ្ធភាពអប់រំ ដោយលើកទឹកចិត្តឱ្យភាគីពាក់ព័ន្ធត្រៀមរៀបចំឱ្យមានការប្រឡងប្រកួតប្រជែងលើផ្នែកបច្ចេកវិទ្យាក្នុងការរៀននិងបង្រៀន។

**វេទិកាពិភាក្សាទី២៖ "ការកែទម្រង់សាលារៀន"** បានដាក់ចេញនូវទិសដៅការងារដូចខាងក្រោម៖

១. កំណែទម្រង់សាលារៀននៅកម្រិតមត្តេយ្យសិក្សា កត្តាគន្លឹះគឺ សាលារៀនត្រូវមានបរិស្ថានស្អាត អនាម័យល្អ វិធីសាស្ត្របង្រៀនថ្មីៗ និងការជឿទុកចិត្តពីមាតាបិតាអ្នកអាណាព្យាបាល ដោយគូសបញ្ជាក់ថា ការវិនិយោគលើលើកុមារតូចពិតជាមានសារៈសំខាន់ពោលគឺ ការវិនិយោគទៅលើអត្តចរិតរបស់ក្មេងដោយបណ្ដុះបំណិនមិនមែនបំណិនវិជ្ជា (Non-Cognitive Skills) គឺការអប់រំអត្តចរិតរបស់សិស្ស និងការលើកទឹកចិត្តភាគីពាក់ព័ន្ធ ឱ្យធ្វើការការវិនិយោគបន្ថែមដល់មត្តេយ្យសិក្សា ដើម្បីឱ្យកុមារតូចនៅកម្ពុជាទទួលបានការលូតលាស់រាយកាយ សុខភាព និងចរិយាមារយាទល្អ។

២. កំណែទម្រង់សាលារៀននៅបឋមសិក្សា កត្តាគន្លឹះគឺ ការអនុវត្តកញ្ចប់អំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង ដោយគ្រូបង្រៀនត្រូវមានសិល្បៈក្នុងការបង្រៀន ត្រូវចេះបង្កើតសម្ភារឧបទេស និងរិះរកវិធីសាស្ត្របង្រៀនថ្មីៗ។ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះរបស់សិស្សបឋមសិក្សាឱ្យបានរឹងមាំ នាយកដ្ឋានជំនាញត្រូវរៀបចំជាឧត្តមានុវត្តន៍ក្នុងការ

អនុវត្តកញ្ចប់អំណាននិងគណិតវិទ្យាថ្នាក់ដំបូង ដើម្បីងាយស្រួលក្នុងការយល់ដឹង និងការអនុវត្តវិធីសាស្ត្របង្រៀន និងការផ្តល់អន្តរាគមន៍គាំទ្រដូចជា ការរៀបចំបណ្ណាល័យឱ្យមានស្តង់ដា និងការប្រើប្រាស់សៀវភៅគោលសិក្សា និងសៀវភៅជំនួយ សម្រាប់បង្កើនគុណភាពសិក្សាបន្ថែម។ ជាមួយគ្នានេះ គ្រូបង្រៀន និងសិស្សានុសិស្សត្រូវស្វែងយល់ច្បាស់អំពីរបៀបរៀនឱ្យបានច្បាស់លាស់ ដូចជា ១).របៀបរៀនសរសេរ និងវេយ្យាករណ៍ ២).ការប្រើប្រាស់ពាក្យ ដើម្បីឱ្យយល់ដឹង និងចាំច្បាស់ ដោយលើកទឹកចិត្តសិស្សឱ្យអានបានច្រើន និងមានប្រព័ន្ធអេកូឡូស៊ីក្នុងការសិក្សា។

៣. កំណែទម្រង់សាលារៀននៅកម្រិតមធ្យមសិក្សា កត្តាគន្លឹះគឺ ការពង្រឹងលទ្ធផលសិក្សារបស់សិស្ស តាមរយៈ ១).ការបង្កើនម៉ោងសិក្សា ២).ការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និង ៣).គណនេយ្យភាព ដែលទាមទារនូវការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងខ្ពស់។ សាលារៀនត្រូវរៀបចំធ្វើតេស្តស្តង់ដា បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន អនុវត្តការរៀនពេញមួយថ្ងៃ បំប៉នទាំងគ្រូបង្រៀន និងសិស្សអំពីការប្រើប្រាស់បច្ចេកវិទ្យាក្នុងការរៀននិងបង្រៀន រៀបចំបរិស្ថានសិក្សាស្អាត ដើម្បីទាក់ទាញសិស្សឱ្យចង់មករៀន ដូចករណីសាលារៀនជំនាន់ថ្មី ជាសាលារៀនដែលមានគុណភាពខ្ពស់ ប៉ុន្តែចំណាយតិច ដោយបានបញ្ចូលការរៀនតាមរយៈការធ្វើពិសោធន៍ ការជំរុញស្វ័យសិក្សា ជាពិសេសការអភិវឌ្ឍសិស្សឱ្យអាចសរសេរសៀវភៅដោយខ្លួនឯងបាន និងថ្មីៗនេះបានបញ្ជ្រាបការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ក្នុងបង្រៀននិងរៀន រៀបចំពិព័រណ៍ស្នាដៃសិស្ស ដើម្បីលើកទឹកចិត្ត និងជួយសិស្សឱ្យចេះស្រមើស្រមៃ និងមានចំណេះដឹងទូលំទូលាយ។

- កំណែទម្រង់សាលារៀនគឺជាទិសដៅសតវត្សទី២១ ដែលយើងទាំងអស់គ្នាត្រូវតែអនុវត្ត ក្នុងន័យថា មានតែការពង្រឹងគុណភាពក្នុងការអប់រំទេ ទើបជួយអ្នកជំនាន់ក្រោយរបស់យើងឱ្យរួចផុតពីភាពក្រីក្រ និងឈានទៅកែប្រែជោគវាសនារបស់ខ្លួនបាន។

**វេទិកាពិភាក្សាទី៣៖ "បរិវត្តកម្មអប់រំឧត្តមសិក្សា"** បានដាក់ចេញនូវទិសដៅការងារដូចខាងក្រោម៖

- នៅកម្រិតឧត្តមសិក្សា ត្រូវចាប់យកឱ្យបាននូវជំនាញបញ្ញាសិប្បនិម្មិត (AI) និងជំនាញស្ទែម (STEAM) ជាពិសេសផ្សារភ្ជាប់ការអប់រំទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីផ្សារការងារ។
- លើកទឹកចិត្តសាកលវិទ្យាល័យឱ្យរៀបចំបង្កើតប្រព័ន្ធអេកូឡូស៊ី ពោលគឺបង្កើតទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងក្រុមហ៊ុនសហគ្រាសនានា ជំរុញឱ្យមានការប្រកួត

ប្រជែង និងបង្កើតជា Start-up លើយន្តការបច្ចេកវិទ្យា ឈានទៅរកការបង្កើតក្រុមហ៊ុន និងការបង្កើតការងារ។

- បណ្តុះបណ្តាលនិស្សិត ឱ្យមានការយល់ដឹងទូលំទូលាយ ស្វែងរកនូវគំនិតថ្មីៗ និងមានភាពក្លាហានក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន។
- ក្រសួងនឹងរៀបចំបង្កើតក្រុមការងារ ដើម្បីពិនិត្យឡើងវិញលើការពង្រឹងការបង្រៀនគណិតវិទ្យា និងស្ថិតិ ដើម្បីឆ្លើយតបនឹងបច្ចេកវិទ្យា និងបញ្ញាសប្បនិម្មិត(AI) នាសតវត្សទី២១ ដោយទាមទារឱ្យសាកលវិទ្យាល័យត្រូវតែមានការកែលម្អជាប្រចាំ។
- សាកលវិទ្យាល័យត្រូវផ្តោតលើការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់និស្សិតឱ្យរឹងមាំ និងវិនិយោគលើការសិក្សាស្រាវជ្រាវ ក្នុងគោលដៅឱ្យនិស្សិតដែលបានបញ្ចប់ការសិក្សាមានចក្ខុវិស័យសិក្សាពេញមួយជីវិត។

***វេទិកាពិភាក្សាទី៤៖ "បរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត"*** បានដាក់ចេញនូវទិសដៅការងារដូចខាងក្រោម៖

១. អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ត្រូវរៀបចំទស្សនាទានស្តីពី មជ្ឈមណ្ឌលសិក្សាសិក្សាពេញមួយជីវិត ដែលមានភាពច្បាស់លាស់ និងប្រាកដនិយម "មើលឱ្យធំ និងដាក់ស្តែង" ដោយផ្អែកលើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ក្នុងគោលដៅផ្តល់ជំនាញដែលចាំបាច់ និងឆ្លើយតបនឹងតម្រូវការទីផ្សារការងារ ជាពិសេសជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងត្រូវផ្សារភ្ជាប់ជាមួយកម្មវិធីណាមួយរបស់សាកលវិទ្យាល័យ សំដៅប្រើប្រាស់ធនធានដែលមានស្រាប់នៅតាមគ្រឹះស្ថានអប់រំសាធារណៈឱ្យអស់ពីលទ្ធភាព។

២. ក្រសួងបានបញ្ចូលកម្មវិធីអភិវឌ្ឍយុវជន ទៅក្នុងការអនុវត្តស្តង់ដាសាលារៀនគំរូតាមរយៈការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា ក្នុងគោលដៅបំពេញបន្ថែម និងដើម្បីសម្រេចបានការបណ្តុះបំណិនសតវត្សទី២១។ កម្មវិធីអភិវឌ្ឍយុវជនដូចជា កម្មវិធីជជែកដេញដោល អ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ យុវជន ២១ និងសហគ្រិនភាព បានបង្រៀនសិស្សឱ្យចេះ និងយល់ ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង បណ្តុះបំណិនដោះស្រាយបញ្ហា ចេះធ្វើស្វ័យសិក្សា ចេះត្រិះរិះពិចារណា និងលើកទឹកចិត្តសិស្សឱ្យចូលរួមក្នុងការប្រកួតប្រជែងផ្សេងៗ។ ជាក់ស្តែង សិស្សដែលបានចូលរួមក្នុងកម្មវិធីអភិវឌ្ឍយុវ

ជនរបស់អគ្គនាយកដ្ឋានយុវជន ទទួលបានបំណិនសតវត្សទី២១ មិនខុសពីសិស្សដែលរៀននៅសាលារៀនជំនាន់ថ្មីឡើយ។

៣. កីឡានាំមកនូវការលូតលាស់ទាំងផ្នែករាយកាយ បញ្ញាស្មារតី អប់រំចរិយាធម៌ សីលធម៌ ពង្រឹងវិន័យ និងបំណិនធ្វើការងារជាក្រុម ក្នុងន័យនេះ ការអប់រំមិនមែនតែក្នុងថ្នាក់រៀនប៉ុណ្ណោះទេ គឺក្តោបលើការលូតលាស់ជារួម ទាំងនៅក្នុង និងក្រៅសាលារៀន និងតាមធម្មជាតិប្រកបដោយភាពវិជ្ជមាន។

៤. ការលើកកម្ពស់សុខភាពសិក្សា និងអាហារតាមសាលារៀនជាផ្នែកមួយនៃយុទ្ធសាស្ត្រគាំពារសង្គម។ ជារួម គោលដៅនៃការអប់រំគឺ ត្រូវធានាបាននូវការអប់រំប្រកបគុណភាព សមធម៌ និងបរិយាបន្ន។

- **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **អង្គសន្និបាតទាំងមូលជាទីមេត្រី**

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការសាងសង់អគារសិក្សា យ៉ាងច្រើនដែលគិតមកដល់ខែមករា ឆ្នាំ២០២៥ មានចំនួន ៤.៥៨២ ខ្នង ស្មើនឹង ៣០.១៣៥ បន្ទប់ ជូនដល់កូនចៅជាសិស្សានុសិស្ស និស្សិត លោកគ្រូ អ្នកគ្រូ។ អគារសិក្សា ថ្នាក់រៀន ការិយាល័យទីចាត់ការ និងផ្ទះគ្រូរបស់សម្តេចមានលក្ខណៈស្តង់ដា មានផាសុកភាព មានបំពាក់គ្រឿងសង្ហារិម បរិក្ខារ សម្ភារៈរៀននិងបង្រៀនគ្រប់គ្រាន់។

ស្ថិតក្នុងបរិយាកាសដ៏រីករាយនេះ យើងខ្ញុំទាំងអស់គ្នាជាមន្ត្រីអប់រំនៅទូទាំង ព្រះរាជាណាចក្រកម្ពុជា សូមសម្តែងនូវការគោរពដឹងគុណ និងចងចាំជានិច្ចចំពោះវីរភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចតេជោអតីតនាយករដ្ឋមន្ត្រី** និងបច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដឹកនាំប្រទេសកម្ពុជាឱ្យមានការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ មានសុខសន្តិភាពពេញលេញ និងមានការអភិវឌ្ឍនៅលើគ្រប់វិស័យ។

ការអភិវឌ្ឍវិស័យអប់រំ គឺជាការងាររួមរបស់រាជរដ្ឋាភិបាលទាំងមូល ទាំងនៅថ្នាក់ជាតិ និងទាំងនៅថ្នាក់ក្រោមជាតិ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ អាជ្ញាធរមូលដ្ឋាន ក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាន មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស និងដៃគូអភិវឌ្ឍផងដែរ។

សមិទ្ធផលដូចបានរៀបរាប់ខាងលើគឺជា លទ្ធផលនៃភាពជាអ្នកដឹកនាំរបស់ **សម្តេចមហាបវរធិបតី** ដែលបំពេញការងារទាំងថ្ងៃ ទាំងយប់ មិនខ្លាចនឿយហត់ក្នុងរយៈពេល១ឆ្នាំកន្លះកន្លងទៅនេះ។ យើងខ្ញុំជាបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ប្តេជ្ញាដើរតាមការដឹកនាំប្រកបដោយគតិ បណ្ឌិត និងជវភាពរបស់ **សម្តេចមហាបវរធិបតី** ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរបស់ **សម្តេចមហាបវរធិបតី** គឺកម្ពុជា ឯករាជ្យ សន្តិភាព និងមានវិបុលភាព។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងអង្គសន្និបាតទាំងមូល ខ្ញុំបាទសូមគោរពជូនពរ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និង **លោកជំទាវបណ្ឌិត** បុត្រា បុត្រី សូមមានសុខភាពល្អ សិរីសួស្តី ជ័យមង្គល និងប្រកបដោយពុទ្ធពរ ៤ ប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ តរៀងទៅកុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំបាទមានកិត្តិយស សូមគោរពអញ្ជើញ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ទីគោរពដ៏ខ្ពង់ខ្ពស់ សូមមេត្តាមានមតិសំណេះ សំណាល ណែនាំ និងផ្តល់អនុសាសន៍ដល់អង្គសន្និបាតទាំងមូលសម្រាប់យកទៅអនុវត្ត និងប្រែក្លាយជាទិសដៅភារកិច្ចឆ្នាំសិក្សាថ្មី ២០២៤ - ២០២៥ និងឆ្នាំសិក្សាខាងមុខ ឱ្យសម្រេចបានជោគជ័យថែមទៀត។

*សូមគោរពអញ្ជើញ !*